**រាជបណ្ឌិត្យសភាកម្ពុជា**

**វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម**

# "និយ័តកម្មទីផ្សារ និង និយ័តកម្មរដ្ឋបាលសម្រាប់ផលិតផលកសិកម្ម" នៅប្រទេសមូលធននិយម


បណ្ឌិត **ឆេង វណ្ណារិទ្ធ**

ប្រធានស្តីទីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម


## សង្ខេបន័យ


កសិកម្ម គឺជាវិស័យមួយដ៏សំខាន់នៅក្នុងសេដ្ឋកិច្ច សង្គម និង នយោបាយនៅក្នុងប្រទេសកម្ពុជា ដែលមានប្រជាជនចំនួន៣,៤៦លាន(៤១,៥%)ប្រកបរបរកសិកម្ម ហើយក្នុងចំណោមអ្នកក្រីក្រភាគច្រើន គឺប្រជាកសិករ។ ក្នុងវិស័យកសិកម្មនេះទៀតសោតតែងតែជួបប្រទះជាមួយនឹងបញ្ហាថ្លៃកសិផលឡើង-ចុះ និងប្រាក់ចំណូលទាបរបស់កសិករ។

វិស័យកសិកម្ម គឺជាវិស័យដែលងាយរងគ្រោះពីធម្មជាតិ ដូចជា ទឹកជំនន់ ភាពរាំងស្ងួត សត្វល្អិត និងគ្រោះមហន្តរាយផ្សេងៗ ដែលអាចជាមូលហេតុធ្វើឱ្យទិន្នផលកសិកម្មទទួលរងនូវការខូចខាត ដូចគ្នានេះដែរក្នុងពេលដែលលក្ខខណ្ឌធម្មជាតិល្អប្រសើរធ្វើឱ្យផលិតផលកសិកម្មកើនឡើងយ៉ាងគំហុក។

វិស័យកសិកម្មនៅប្រទេសកម្ពុជានៅតែបន្តជួបបញ្ហាប្រឈមដូចជា ភាពងាយរងគ្រោះនៃប្រព័ន្ធជាំដុះ ផលិតភាពនិងតម្លៃបន្ថែមនៅទាប បច្ចេកវិទ្យាដាំដុះនិងការប្រើប្រាស់ជាតុចូលតាមបច្ចេកទេសនៅមានកម្រិត ជាពិសេសថ្លៃនិងប្រាក់ចំណូលនៅក្នុងវិស័យកសិកម្មទទួលរងនូវការឡើងចុះយ៉ាងខ្លាំងពីការប្រែប្រួលស្ថានភាពទីផ្សារ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពប្រជាកសិករខ្មែរ។

ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យកសិកម្ម ចាំបាច់ត្រូវមានគោលនយោបាយកសិកម្ម និងការឧបត្ថម្ភធនរបស់រដ្ឋាភិបាល តួយ៉ាងដូចនៅបណ្តាប្រទេសនៃសហគមន៍អឺរ៉ុប ក៏ដូចជានៅសហរដ្ឋអាម៉េរិកជាដើម។

ជាច្រើនទសវត្សរ៍កន្លងមកហើយ អ្នកនយោបាយនិងអ្នកសេដ្ឋកិច្ចបានជជែកអំពីយន្តការដែលល្អជាងគេ ផែនការឬទីផ្សារ? ទន្ទឹមគ្នានេះដែរ នៅបណ្តាប្រទេសនៃអឺរ៉ុបខាងលិច បានបង្កើតឡើងនូវម៉ូដែលធ្វើសេដ្ឋ-កិច្ចផ្អែកលើយន្តការនិយ័តកម្មទីផ្សារដែលគួបផ្សំនូវសមាសធាតុផែនការកម្ម(planning) ឬក៏និយ័តកម្មរដ្ឋបាល

(administrative regulation)។ ក្នុងវិស័យមួយចំនួននៃសេដ្ឋកិច្ចជាតិ សមាសធាតុផែនការកម្មមានតិចតួច តែក្នុងវិស័យមួយចំនួនទៀត សមាសធាតុផែនការកម្ម គឺមានទំហំធំធេង។

វិស័យកសិកម្ម គឺជាវិស័យពិសេសមួយនៃសេដ្ឋកិច្ចជាតិ ដែលក្នុងនោះមានការទាក់ទងគ្នានូវកត្តាជីវៈចម្រុះធម្មជាតិ កត្តាបច្ចេកទេសនិងបច្ចេកវិទ្យា កត្តាសេដ្ឋកិច្ចនិងសង្គម និងកត្តាដទៃទៀត។ កម្លាំងផលិតកម្មដ៏សំខាន់ក្នុងវិស័យកសិកម្ម គឺកសិករដែលជាផលិតករនិងអ្នកថែរក្សាតម្លៃវប្បធម៌របស់ជាតិ ដូចជា ភាសា ទំនៀមទម្លាប់ ប្រពៃណីជាតិ ជាដើម។ ដូច្នេះហើយ កសិករនិងវិស័យផលិតកម្មរបស់ពួកគេ គឺមិនអាចត្រូវរងគ្រោះពីកម្លាំងទីផ្សារ ក៏ដូចជាការដាក់បញ្ញារដ្ឋបាលពីភាគីអង្គការរដ្ឋឡើយ។ ផ្អែកលើទស្សនៈខាងលើនេះហើយដែល វិស័យកសិកម្មនៅក្នុងប្រទេសមូលធននិយមត្រូវបានស្ថាបនាឡើង ផ្អែកលើទំនាក់ទំនងការជ្រោមជ្រែងគ្នាទៅវិញទៅមករវាងនិយ័តកម្មទីផ្សារនិងនិយ័តកម្មរដ្ឋបាលសម្រាប់ផលិតកម្មនិងការលក់ដូរកសិផល។

ជាការពិត អន្តរាគមន៍របស់រដ្ឋនៅក្នុងវិស័យកសិកម្មកើតមានឡើងកាលពីមុនពេលកកើតឡើងនូវទំនាក់ទំនងមូលធននិយមក្នុងវិស័យកសិកម្មនៅក្នុងពាក់កណ្ដាលទីពីរនៃសតវត្សរ៍ទីXX ដែលពេលនោះប្រព័ន្ធនិយ័តកម្មរបស់រដ្ឋនៅក្នុងវិស័យកសិកម្មត្រូវបានបង្កើតឡើងនិងរាលដាលយ៉ាងទូលំទូលាយ។

យន្តការទីផ្សារដែលផ្អែកលើច្បាប់សេដ្ឋកិច្ចជាសកល ជាពិសេសច្បាប់ផលិតកម្មទំនិញ(commodity production)ដែលមានឥទ្ធិពលក្នុងលក្ខខណ្ឌប្រកួតប្រជែងនៅលើទីផ្សារក្នុងស្រុក ទីផ្សារតំបន់ ទីផ្សារជាតិ និងនៅលើកម្រិតទីផ្សារអន្តរជាតិផងដែរ បានបង្ខំកសិករបន្ទាបជាប្រចាំនូវចំណាយថ្លៃដើមផលិតកម្ម ស្វែងរកវិធីផលិតកម្មដែលមានប្រសិទ្ធភាពខ្ពស់ លើកកម្ពស់ភាពដែលអាចឱ្យផលចំណេញ(profitability)នៃការងារធុរកិច្ចរបស់ខ្លួន ក្នុងគោលបំណងរក្សាបាននិងពង្រឹងស្ថានភាពរបស់ខ្លួនក្នុងវិស័យកសិកម្ម។ យន្តការទីផ្សារប្រសិនរដ្ឋាភិបាលមិនមានវិធានពិសេសទប់ស្កាត់ នោះវាជួយផ្ដត់ផ្ដង់កំណើនផលិតកម្ម ធ្វើឱ្យមាននូវអតិរេកទំនិញដែលផលិតបានក្នុងកំលុងពេលជាក់លាក់ ឬក៏អាចបញ្ច្រាស់មកវិញ។ ទន្ទឹមគ្នានេះដែរ យន្តការទីផ្សាក៏លុបបំបាត់នូវអង្គភាពផលិតកម្មដែលមិនសូវមានប្រសិទ្ធភាព រុញច្រានចេញពីវិស័យកសិកម្មចំពោះអ្នកទាំងឡាយដែលគ្មានសមត្ថភាពដើរដោយខ្លួនឯងជាមួយនឹងការរីកចម្រើនវិទ្យាសាស្ត្រ-បច្ចេកវិទ្យា និងសេដ្ឋកិច្ច។

និយ័តកម្មរដ្ឋបាល ឬនិយ័តកម្មរដ្ឋ(administrative, or government regulation)ទៅលើផលិកម្មនិងការលក់ដូរផលិតផលកសិកម្ម មានគោលបំណងមួយចំនួន ដែលត្រូវបានបង្កើតឡើងក្នុងកម្មវិធីរបស់រដ្ឋាភិបាល ហើយត្រូវបានផ្ដល់ហិរញ្ញប្បទានពីថវិកាជាតិ។

ក្នុងអំឡុងឆ្នាំ១៩៤៧-១៩៦០ នៅប្រទេសស៊ុយអ៊ែត(Sweden), ហូឡង់(Netherlands), អង់គ្លេស(United Kingdom), ស្វីស(Switzerland), អាល្លឺម៉ង់(Germany), អូទ្រីស(Australia), បែលហ្សិក(Belgium) និងបារាំង(France)គេបានអនុម័ត"ច្បាប់វិស័យកសិកម្ម"។ នៅក្នុងច្បាប់នោះបានកំណត់គោលបំណងនៃគោលនយោបាយកសិកម្ម។ ឧទាហរណ៍"ច្បាប់កសិកម្ម" ឆ្នាំ១៩៥៥ របស់អាល្លឺម៉ង់បានចែងនូវមាត្រាគោលនយោបាយកសិកម្ម ដូចជា៖

- លទ្ធភាពប្រើប្រាស់កាន់តែប្រសើរឡើងនូវកត្តាផលិតកម្មក្នុងវិស័យកសិកម្ម និង ផ្គត់ផ្គង់ថ្លៃសមរម្យដល់អ្នកប្រើប្រាស់
- ផ្គត់ផ្គង់កម្រិតជីវភាពសមរម្យសម្រាប់អ្នកដែលប្រកបរបរកសិកម្ម ក៏ដូចជាលើកកម្ពស់ស្ថានភាពសង្គមរបស់ពួកគេដល់កម្រិតជៀបគ្នានិងក្រុមមានជំនាញ
- ស្ថិរភាវូបនីយកម្មទីផ្សារកសិផល

- ផ្គត់ផ្គង់ការដឹកជញ្ជូនទំនិញស្បៀង(food commodities) ។ល។

ជាមួយគ្នានេះដែរ ការឱ្យសច្ចាប័ននៃកិច្ចព្រមព្រៀងរបស់សហភាពអឺរ៉ុបឆ្នាំ១៩៥៧ ដែលកំណត់បន្ថែមនូវគោលនយោបាយកសិកម្មដូចជា៖

- ផ្គត់ផ្គង់សុខភាពប្រជាពលរដ្ឋដោយផលិតផលកសិកម្មដោយគ្មានលក្ខខណ្ឌ
- ចូលរួមចំណែកការពារ ថែរក្សា អភិវឌ្ឍ និងទេសភាពធម្មជាតិ
- ចូលរួមចំណែកទ្រទ្រង់ភាពអាចផ្តល់ផលចំណេញសម្រាប់វិស័យកសិកម្មនៅតំបន់ជនបទ។

ទិសដៅសកម្មភាពនៃនិយ័តកម្មយន្តការទីផ្សារនិងនិយ័តកម្មយន្តការរដ្ឋបាលទៅលើផលិតកម្មកសិកម្មអាចស្របគ្នា ប៉ុន្តែ ក៏អាចមានភាពផ្ទុយគ្នា។ នៅបណ្តាប្រទេសអឺរ៉ុបខាងលិច ក្នុងអំឡុងឆ្នាំដំបូងក្រោយសង្គ្រាម តម្រូវការលើទំនិញស្បៀងត្រូវបានឡើងខ្ពស់ ទាំងនិយ័តកម្មយន្តការទីផ្សារ ក៏ដូចជាទាំងនិយ័តកម្មយន្តការរដ្ឋបាលទៅក្នុងវិស័យកសិកម្មបានធ្វើសកម្មភាពក្នុងទិសដៅតែមួយ គឺបានជួយឱ្យមានកំណើនបរិមាណផលិតផលកសិកម្ម។ កត្តានេះជួយផ្តល់អត្ថប្រយោជន៍ដល់អ្នកចូលរួមសំខាន់ៗគ្រប់រូបទាំងអស់ក្នុងទំនាក់ទំនងកសិកម្ម ដូចជា កសិករនិងកសិដ្ឋាន រដ្ឋ កម្មសិទ្ធិករដីធ្លី ម្ចាស់ទុនសំណុំកសិ-ឧស្សាហកម្ម(agro-industrial complex) ក៏ដូចដល់អ្នកប្រើប្រាស់។ ភាពស្របគ្នានៃអត្ថប្រយោជន៍ និងឆន្ទៈដើម្បីពង្រីកផលិតកម្មដូចនេះ បានធ្វើឱ្យប្រទេសជាច្រើនសម្រេចបាននូវផលិតកម្មទំនិញកសិផលសំខាន់ៗដល់កម្រិតមុនពេលសង្គ្រាម។

ចរិតលក្ខណៈផ្ទុយនៃសកម្មភាពនិយ័តកម្មយន្តការទីផ្សារនិងនិយ័តកម្មរដ្ឋបាលទៅលើផលិតកម្ម ត្រូវបានលេចចេញឡើងទៅតាមការពង្រីកនៃការប្រើប្រាស់វិធីរដ្ឋបាលនិយ័តកម្ម នោះឥទ្ធិពលច្បាប់ទីផ្សារត្រូវបានរួមតូច ដូចជា ការអនុវត្តថ្លៃធានាសម្រាប់ផលិតផលកសិកម្មថ្មីៗទាំងអស់ បង្រួមឱ្យកាន់តែតូចនូវឥទ្ធិពលច្បាប់តម្លៃ(law of value)។ ក្នុងការប្រកួតប្រជែងដោយសេរីនៃកម្លាំងទីផ្សារ តម្រូវការនិងការផ្គត់ផ្គង់ ជាទូទៅធ្វើឱ្យមានសមតា។ ការកំណត់ថ្លៃធានាទិញ(guaranteed purchasing price)នៅលើកម្រិតថ្លៃខ្ពស់ជាងចំណាយថ្លៃដើមចាំបាច់ទូទៅសម្រាប់ផលិតកម្ម គឺធ្វើឱ្យស្ថានភាពការផ្គត់ផ្គង់កសិផលលឿនជាងតម្រូវការ។ បាតុភូតនេះត្រូវបានគេសង្កេតឃើញនៅក្នុងបណ្តាប្រទេសទីផ្សាររួមអឺរ៉ុប ដែលនៅទីនោះត្រូវបានបង្ហាញហេតុផលដែលអង្គការរដ្ឋបង្ខំចិត្តដាក់កំហិតនូវកំណើនផលិតកម្មកសិផល។

ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ នៅក្នុងបណ្តាប្រទេសទីផ្សាររួមអឺរ៉ុប កម្រិតនៃការផ្គត់ផ្គង់ដោយខ្លួនឯងនូវផលិតផលកសិកម្ម គឺត្រូវបានឡើងខ្ពស់យ៉ាងខ្លាំង។ ប្រភេទទំនិញស្បៀងសំខាន់ៗ( ធុញ្ញជាតិ, សាច់គោ, ខ្លាញ់ធ្វើពីទឹកដោះគោ, ម្សៅទឹកដោះគោ, ស្រាទំពាំងបាយជូរ និង ប្រេងអូលីវ ) ត្រូវបានផលិតលើសពីតម្រូវការ។

នៅសហរដ្ឋអាម៉េរិក ការផលិតលើសក្នុងវិស័យកសិកម្ម បានកើតមានឡើងក្នុងឆ្នាំ១៩៨០ ដែលលទ្ធផលធ្វើឱ្យប្រាក់ចំណូលរបស់កសិករត្រូវបានកាត់បន្ថយយ៉ាងខ្លាំង[1]។ យន្តការនិយ័តកម្មទីផ្សារផលិតកម្ម ដូចបានបញ្ជាក់ពីខាងដើម គឺមានឥទ្ធិពលក្នុងទិសដៅតែមួយ គឺជួយឱ្យមានកំណើនទាំងបរិមាណនិងទាំងគុណភាពនៃផលិតផល។ ក្នុងអំឡុងឆ្នាំ១៩៦៥-១៩៨៥ នៅក្នុងបណ្តាប្រទេសទីផ្សាររួមអឺរ៉ុប បរិមាណផលិតផលកសិកម្មកើនឡើងប្រមាណជា៤០%ដែលគិតជាមធ្យម គឺកើនឡើងប្រមាណជា២%ក្នុងមួយឆ្នាំ។ បរិមាណ

[1] Саусановичус А. И., Демин А. А. Экономика сельского хозяйства// Экономики «разных скоростей». Капиталистические и развивающиеся страны : Очерки / Под ред. А. А. Демина. Л., 1990. С 97-106. ( ប្រភព : «ГОСУДАРСТВО И РЫНОК», Издательство С.-Перербургского Университета, С.ПЕТЕРБУРГ, 1995, ទំព័រ ១៨៥ )

ផលិតផលដំណាំក្នុងប្រទេសចំនួន១០ នៃបណ្ដាប្រទេសទីផ្សាររួមអឺរ៉ុបក្នុងអំឡុងឆ្នាំ១៩៦៥-១៩៨៥ ត្រូវបានកើនឡើងជាមធ្យម២,៣% ចំណែកឯតម្រូវការលើផលិតផលដំណាំទាំងនោះ គឺមានត្រឹមតែ០,៥%ប៉ុណ្ណោះក្នុងមួយឆ្នាំ ដោយហេតុនេះតម្រូវឱ្យមានភាពចាំបាច់ក្នុងការកាត់បន្ថយផ្ទៃដីដាំដុះ១,៨%ក្នុងមួយឆ្នាំ។ ជាក់ស្ដែងការកាត់បន្ថយផ្ទៃដីដាំដុះក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ គឺមានត្រឹមតែ០,៤៤%ប៉ុណ្ណោះ។ តួលេខនេះបញ្ជាក់ឱ្យដឹងថាដើម្បីឱ្យមានសមតាតម្រូវការនិងការផ្គត់ផ្គង់នៅក្នុងបណ្ដាប្រទេសទីផ្សាររួមអឺរ៉ុបក្នុងអំឡុងពេលទសវត្សរ៍ខាងមុខ គេត្រូវតែកាត់បន្ថយផ្ទៃដីដាំដុះ១៥%[2]។

នៅសហរដ្ឋអាម៉េរិក បរិមាណផលិតផលកសិកម្មមានកំណើនយឺតជាង ធៀបជាមួយនឹងប្រទេសទីផ្សាររួមអឺរ៉ុប។ ក្នុងអំឡុងឆ្នាំ១៩៧៩-១៩៨៨ តម្លៃផលិតផលដំណាំ និង ការចិញ្ចឹមសត្វ នៅសហរដ្ឋអាម៉េរិក( ដោយមិនគិតជាមួយនូវការទូទាត់របស់រដ្ឋដោយផ្ទាល់ដល់កសិករ )បានឡើងពី១៣១,៥ប៊ីលានដុល្លារដល់១៥០ប៊ីលានដុល្លារ ឬ ១៤% មានន័យថាកំណើនជាមធ្យម គឺ១,៥៦%[3]។

នៅក្នុងប្រទេសមូលធននិយមភាគច្រើន មានការព្យាករណ៍សេដ្ឋកិច្ចដែលមានទឡ្ហីករណ៍គ្រប់គ្រាន់អំពីការរីកចម្រើននៃរចនាសម្ព័ន្ធវិស័យកសិកម្មក្រោមឥទ្ធិពលយន្តការីផ្សារដែលមានស្រាប់។ ការិយាល័យវាយតម្លៃបច្ចេកវិទ្យារបស់ព្រឹទ្ធសភាសហរដ្ឋអាម៉េរិក(United States Congerss Office of Technology Assessment) បានគណនាឱ្យដឹងថា ចំនួនកសិដ្ឋានក្នុងអំឡុងពេលពីឆ្នាំ១៩៨២-២០០០ ត្រូវបានកាត់បន្ថយពី២,២៤ លានមកត្រឹម ១,២៥លាន ឬ ៤៥%[4]។

ក្រោមឥទ្ធិពលកម្លាំងទីផ្សារ កសិដ្ឋានតូចៗជាច្រើននៅភាគខាងត្បូងអឺរ៉ុបត្រូវបានលុបបំបាត់ចោលដោយសារតែកម្លាំងផលិតកម្មនៅទីនោះមានការប្រមូលផ្ដុំខ្ពស់ ហើយចំនួនកសិដ្ឋានដែលកំពុងតែដំណើរការត្រូវបានសន្និដ្ឋានថា ក្នុងឆ្នាំ២០០០ ត្រូវបានលុបបំបាត់ចោលពី១/៣ ដល់១/២ ។ ជាមួយគ្នានេះដែរ ផ្ទៃដីដាំដុះចំនួន៣០%ដែលកំពុងប្រើប្រាស់ នឹងត្រូវបានដកហូតពីការប្រើប្រាស់សម្រាប់វិស័យកសិកម្ម ដោយសារតែកង្វះឬគ្មានតម្រូវការលើផលិតផលកសិកម្ម។ សហគ្រាសដែលរងគ្រោះជាងគេ គឺសហគ្រាសដែលស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចនិងលក្ខខណ្ឌធម្មជាតិមិនប្រសើរ ហើយក្នុងលក្ខខណ្ឌបែបនេះក៏មានការកើតឡើងយ៉ាងខ្លាំងនូវការប្រមូលផ្ដុំផលិតកម្មទៅក្នុងសហគ្រាសដែលមានស្ថានភាពល្អប្រសើរជាងគេក្នុងវិស័យនេះ។

ការតស៊ូដើម្បីការរស់នៅលើទីផ្សារកសិកម្មប៉ែកខាងលិចនឹងមានភាពតានតឹងដល់កម្រិត ទាល់តែកសិដ្ឋានដែលមានរចនាសម្ព័ន្ធផលិតកម្មត្រឹមត្រូវនោះទើបអាចទ្រទ្រង់ដំណើរការបានយូរអង្វែង។ ធនធានមួយចំណែកធំដែលបានចំណាយដើម្បីទ្រទ្រង់ទីផ្សារ នាពេលខាងមុខត្រូវតែចំណាយសម្រាប់គោលនយោបាយជារចនាសម្ព័ន្ធនិងផ្គត់ផ្គង់សកម្មភាពរបរកសិកម្មនៅតំបន់ដែលមានលក្ខខណ្ឌមិនល្អ។ ដោយហេតុថា មិនមែនផ្ទៃដីដាំដុះទាំងអស់ដែលបានរំដោះចេញឱ្យនៅទំនេរ ត្រូវបានយកទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេងតាម

---

[2] Henrichsmever W., Ostermeyer – Schöder A., Productivity growth and factor adjustment in EC agriculture || European review of agricultural economics. 1988, № 2-3. P. 137, 150.

[3] Agricultural Outlook.Washington. August 1989. P. 49. សូមបញ្ជាក់ថា នៅសហភាពសូវៀត ផលិតផលកសិកម្មជាមធ្យមប្រចាំឆ្នាំ គិតតាមថ្លៃដូចគ្នានេះ កើនឡើងពី១៧៦ប៊ីលានរូប្ល ដល់ ២០០ ប៊ីលានរូប្ល ក្នុងអំឡុងឆ្នាំ១៩៧១-១៩៧៥ ដល់ ១៩៨៦ - ១៩៨៨ ពោលកើនឡើងជាមធ្យម ២,៦%ក្នុងមួយឆ្នាំ ( Народное хозяйство СССР в 1988 г. М., 1989. С. 426).

[4] Monatsberichte Über die österreichische Landwirtschaft. Wien,1988. H. 7. S. 446

រយៈឧបត្ថម្ភធន ដូចជា ការដាំដើមឈើជាគម្រប ជាដើម ត្បិតអីនៅអឺរ៉ុបខាងលិចមានផ្ទៃដីកាន់តែធំបានកើតមានឡើង ដែលអាចវិលត្រឡប់ទៅស្ថានភាពធម្មជាតិដូចគ្រាដើម[5]។

ក្រោមឥទ្ធិពលកម្លាំងទីផ្សារនិងវឌ្ឍនភាពវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និយ័តកម្មរដ្ឋបាលត្រូវបានកំណត់កម្រិតអប្បបរមាសម្រាប់ទ្រទ្រង់ជីវិតឬជីវភាព និងព្រំដែនដែលអាចទទួលផលចំណេញសម្រាប់របរកសិកម្មដោយផ្អែកលើបរិមាណផលិតផលជាក់លាក់។ ឧទាហរណ៍ នៅប្រទេសអាល្លឺម៉ង់ ព្រំដែនអប្បបរមានៃភាពអាចទទួលបានផលចំណេញ គឺរបរកសិកម្មដែលមានទំហំដី៣៥ហិកតា(ទំហំនេះអាចកែតម្រូវតាមតំបន់)។ នៅបាវ៉ារី គឺកំណត់ទំហំ២៥ហិកតា នៅតំបន់ខ្លះរហូតដល់៥០ហិកតា[6]។ កម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ចមានចិរភាពត្រូវបានចាត់ទុកទំហំប្រាក់ចំណូលសរុប៥០-៦០ពាន់អឺរ៉ូ និងការបង្កើតមូលធនជាកម្មសិទ្ធិផ្ទាល់ខ្លួន(ការវិនិយោគ) ប្រចាំឆ្នាំស្មើនឹង១០-២០អឺរ៉ូ។ ប៉ុន្តែក្នុងឆ្នាំ១៩៨៨-១៩៨៩ មានតែអង្គភាព៤១%ប៉ុណ្ណោះ ដែលអាចសម្រេចបានទំហំវិនិយោគ១០ពាន់អឺរ៉ូ។ ជាមួយគ្នានេះដែរ អង្គភាព៤១%ទៀតបានបាត់បង់មូលធនផ្ទាល់ខ្លួន[7]។ មានន័យថា យន្តការទីផ្សារបន្តឱ្យមានភាពរំជើបរំជួលដល់ផ្នែកសេដ្ឋកិច្ចនិងដល់ពេលដែលធុរជនត្រូវការជំនួយសង្គមពីភាគីរដ្ឋាភិបាលទាក់ទងនឹងការកាត់បន្ថយផលិតកម្ម។

នៅក្នុងនិយ័តកម្មរដ្ឋបាលសម្រាប់វិស័យកសិកម្ម គេអនុវត្តវិធីបង្គាប់បញ្ជា និង មិនបង្គាប់បញ្ជា។ តាមទិន្នន័យកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធនិងពាណិជ្ជកម្ម (General Agreement on Tariffs and Trade, GATT) នៅក្នុងប្រទេសមូលធននិយម គឺមានវិធានការជាង៨០ផ្សេងៗគ្នាដែលមានឥទ្ធិពលទៅលើដំណើរការផលិតកម្មនៅក្នុងវិស័យកសិកម្ម ហើយត្រូវបានយកមកប្រើប្រាស់។ នាពេលបច្ចុប្បន្ន វិធីបង្គាប់បញ្ជា(directive method) នៅក្នុងនិយ័តកម្មរបស់រដ្ឋាភិបាលសម្រាប់វិស័យកសិ-ឧស្សាហកម្ម មានដូចជា កូតាផលិតទឹកដោះគោ ស្ករស គុណភាពផលិតផល ជាដើម។ វិធីនិយ័តកម្មភាគច្រើនផ្អែកលើការជំរុញទឹកចិត្តសេដ្ឋកិច្ចដល់ផលិតករ។ អង្គការរដ្ឋបង្កើតប្រព័ន្ធជាក់លាក់សម្រាប់លើកទឹកចិត្តជាសម្ភារៈ ដែលតាមរយៈយន្តការនេះផលិតករពង្រីក ឬ កាត់បន្ថយបរិមាណផលិតកម្មប្រភេទទំនិញណាមួយ(បន្ទាប ឬ ដំឡើងថ្លៃទិញ កំណត់ការឧបត្ថម្ភសម្រាប់ផលិតការនាំចេញ និងពន្ធគយ រង្វាន់លើកទឹកចិត្តទាក់ទងនឹងការកែច្នៃផលិតផលពីប្រភេទមួយ ទៅប្រភេទមួយ រង្វាន់លើកទឹកចិត្ត និងប្រាក់ឧបត្ថម្ភចូលនិវត្តន៍ក្នុងពេលបញ្ឈប់ផលិតកម្មទាំងស្រុង ជាដើម)[8]។

នៅក្នុងលក្ខខណ្ឌកាន់តែលំបាកក្នុងការលក់ដូរ អង្គការរដ្ឋផ្តោតការខិតខំប្រឹងប្រែងរបស់ខ្លួនមិនមែនទៅលើកំណើនបរិមាណផលិតកម្មនោះទេ ប៉ុន្តែទៅលើប្រសិទ្ធភាពផលិតកម្មកសិកម្ម ពោលរដ្ឋាភិបាលអនុវត្តគោលនយោបាយសារពើពន្ធ គោលនយោបាយឥណទាន គោលនយោបាយជារចនាសម្ព័ន្ធនិងសង្គម ក៏ដូចជាគោលនយោបាយលើកទឹកចិត្តសំដៅវឌ្ឍនភាពបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ(Scientific and Technological Progress, STP) និងទ្រទ្រង់ថ្លៃទំនិញម្ហូបអាហារ(food commodities)។

---

[5] Thied C. Landwirtschaftliche Vielfach in Europa – Wirtschaftliche und soziale Perspektiven // Geschäfts – und Arbeitsbericht der Agrarsonzialen Gesellschaft e. V. Göttingen fÜr das jahr 1988. Göttingen, 1988. S. 19.

[6] Strukturwandel weiter wirksan // Krafrfutter. Hannover, 1989. Nr.2. S. 35.

[7] Bauern haben etwas Luft geholt, aber … // Landwirtschaftlches Wochenblatt Westfalen-Lippe. Münster, 1989. Nr. 51. S.16. (ប្រភព : «ГОСУДАРСТВО И РЫНОК», Издательство С.-Перербургского Университета, С.ПЕТЕРБУРГ, 1995, ទំព័រ ១៨៦)

[8] លោកសាស្ត្រាចារ្យ សេដ្ឋវិទូ Э. Бёкенхофа បានបញ្ជាក់ថា ប្រមាណជា៤០%នៃប្រាក់ចំណូលវិស័យកសិកម្មក្នុងប្រទេសអាល្លឺម៉ង់កើតឡើងដោយសារផលិតផលដែលទទួលរងនូវនិយ័តកម្មបង្គាប់បញ្ជាមានកម្រិត។ នៅក្នុងប្រទេសសហគមន៍អឺរ៉ុបផ្សេងទៀត សន្ទស្សន៍នេះ គឺទាបជាងនេះ។(- ដ -)

នៅក្នុងបណ្ដាប្រទេសនៃសហគមន៍អឺរ៉ុប ក្រោមនិយ័តកម្មរបស់រដ្ឋ(government regulation)ថ្នាក់ជាតិនិងក្រោមជាតិ គឺក្រសោប ៩៨%នៃផលិតផលកសិកម្មដែលបានផលិត ក្នុងចំណោមនោះ ៣/៤ នៃផលិតផលត្រូវបានកំណត់ថ្លៃធានា(guaranteed price)។ គប្បីកត់សម្គាល់ថា ក្នុងចំណោមវិធីជាច្រើននៃនិយ័តកម្មទៅលើផលដំណាំកសិកម្ម គឺការកំណត់ថ្លៃដែលត្រូវបានចាត់ទុកជាមុខងារពិសេស។

ការបន្ទាបថ្លៃធានាទិញឬបន្ទុះបង្អាប់ផលិតផលកសិកម្ម គឺជាការដាក់កំហិតនូវការកើនឡើងនៃបរិមាណផលិតកម្មក្នុងវិស័យនេះ។ ក្នុងស្ថានភាពបែបនេះ ផលប្រយោជន៍របស់កសិករនិងផលប្រយោជន៍របស់រដ្ឋ គឺផ្ទុយគ្នា។ ការបញ្ចុះថ្លៃផលិតផលកសិកម្ម ឬក៏ការដាក់កំហិតបរិមាណផលិតផលកសិកម្ម គឺផលវិបាកចៀសមិនផុតពីការធ្លាក់ចុះប្រាក់ចំណូលរបស់កសិករ។ ដើម្បីរក្សាផលប្រយោជន៍របស់ខ្លួន កសិករគ្មានចេតនាកាត់បន្ថយផលិតកម្មរបស់ពួកគេឡើយ ផ្ទុយមកវិញគ្រាដែលថ្លៃកាន់តែទាបលើផលិតផលកសិកម្ម នោះកសិករព្យាយាមបំពេញសំណងពីការបាត់បង់ប្រាក់ចំណូលនេះ ដោយវិធីបង្កើនផលិតផលផ្គត់ផ្គង់នៅលើទីផ្សារកាន់តែច្រើន។ ដូច្នេះហើយ ធន្ទះរបស់រដ្ឋាភិបាលដាក់កំហិតផលិតកម្មទទួលបានជោគជ័យ ដរាបណារដ្ឋាភិបាលទូទាត់សំណងគ្រប់គ្រាន់ដល់កសិករ ដែលបាត់បង់ប្រាក់ចំណូលពីស្ថានភាពទីផ្សារ និងគោលនយោបាយរបស់រដ្ឋាភិបាល តាមរយៈបង់ប្រាក់ជូនកសិករ ដែលប្រាក់ទាំងនោះបានពីថវិកាជាតិ។

គំរូផ្គុំគ្នាប្រកបដោយជោគជ័យរវាងវិធីនិយ័តកម្មបែបរដ្ឋបាលនិងការធានារ៉ាប់រងសង្គមកិច្ចសម្រាប់កសិករពីភាគីរដ្ឋាភិបាល គឺមានដូចជាការដាក់កំហិតកូតាសម្រាប់ផលិតកម្មទឹកដោះគោក្នុងឆ្នាំ១៩៨៤ នៅប្រទេសទីផ្សាររួមអឺរ៉ុប។ ចាប់ពីឆ្នាំ១៩៨៣/៨៤ដល់ឆ្នាំ១៩៨៨/៨៩ ទឹកដោះគោប្រចាំឆ្នាំដែលបានផ្គត់ផ្គង់នៅលើទីផ្សារក្នុងប្រទេសចំនួន១០នៃហគមន៍អឺរ៉ុប ត្រូវបានកាត់បន្ថយពី១០៣,៤លានតោន មកត្រឹម៩៣,៥លានតោនប៉ុណ្ណោះ[9]។ ជោគជ័យនៃកម្មវិធីនេះ ជាមួយនឹងការកំណត់កូតាផលិតកម្មសម្រាប់បុគ្គល សម្រាប់កសិករត្រូវបានរដ្ឋាភិបាលផ្ដល់នូវលក្ខខណ្ឌដ៏ល្អប្រសើរជូនដល់កសិករជំនួសការកាត់បន្ថយផលិតកម្មរបស់ខ្លួន។ កសិករជាច្រើនបានទទួលយកប្រាក់រង្វាន់លើកទឹកចិត្តជំនួសការកាត់បន្ថយផលិតផលទឹកដោះគោរបស់ខ្លួន។

ឧទាហរណ៍"ផលិតកម្មប្រេងឆា" ធ្វើឱ្យប្រទេសសហគមន៍អឺរ៉ុបចំណាយប្រាក់អស់ជាច្រើនសម្រាប់រក្សាទុកផលិត ផលទាំងនោះ។ ក្នុងឆ្នាំ១៩៨៦ ប្រេងឆាដែលលក់មិនអស់ ហើយត្រូវបានរក្សាទុកក្នុងឃ្លាំងនៅប្រទេសសហ-គមន៍អឺរ៉ុប គឺមានចំនួន១,៤លានតោន ហើយដោយសារតែវិធានការបែបនេះ មកដល់ខែកញ្ញា ឆ្នាំ១៩៨៩ ធ្វើឱ្យប្រេងឆាដែលទុកបម្រុងត្រូវបានកាត់បន្ថយមកត្រឹម ២៦៣ពាន់តោនប៉ុណ្ណោះ។

និយ័តកម្មរដ្ឋបាលនៅក្នុងវិស័យកសិ-ឧស្សាហកម្ម គឺជាផ្នែកមួយដ៏សំខាន់នៃគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាលនៃបណ្ដាប្រទេសមូលធននិយម។ គោលនយោបាយកសិកម្ម ក៏ដូចជាគោនយោបាយទាំងឡាយផ្សេងទៀត គឺត្រូវចំណាយប្រាក់អស់ជាច្រើន ដូចជា នៅដើមឆ្នាំ១៩៨០ ចំណាយសម្រាប់ទ្រទ្រង់វិស័យកសិកម្មនៅប្រទេសជប៉ុនគឺមានចំនួន២,៩%នៃផលិតផលក្នុងស្រុកសរុប នៅក្នុងប្រទេសសហគមន៍អឺរ៉ុប ២,៨% នៅប្រទេសនូវែលសេឡង់១,៤% នៅសហរដ្ឋអាម៉េរិក១,៣% នៅកាណាដា១,២%[10]។ ក្នុងឆ្នាំ១៩៨៨ នៅបណ្ដាប្រទេសអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍(Organization for Economic Cooperation and Development, OECD)ចំណាយរបស់រដ្ឋសម្រាប់ទ្រទ្រង់វិស័យកសិកម្ម គឺចំនួន២៤០ប៊ី

[9] Richards E. Fünf Jahre Feform der Milchmarktpolitik // Kraftfutter. Hannover, 1989. Nr. 6. S. 241. ( - ជ - )

[10]Agriculture in the GATT: an analysis of alternative approaches to reform. Washingtob,1988. P. 16. ( - ជ - )

លានដុល្លារ[11]។ រយៈពេលច្រើនឆ្នាំនៅក្នុងបណ្តាប្រទេស OECD បានប្រើប្រាស់សូចនាករថ្មីដើម្បីបង្ហាញនូវនិយ័តកម្មរដ្ឋបាលស៊ីជម្រៅសម្រាប់វិស័យកសិកម្ម គឺអេគ្វីវ៉ាឡង់ឧបត្ថម្ភធនផលិតករ(Producer Subsidy Equivalent, PSE)[12]។ អេគ្វីវ៉ាឡង់ឧបត្ថម្ភធនផលិតករ( Producer Subsidy Equivalent, PSE)បង្ហាញនូវមួយផ្នែកនៃតម្លៃផលិតផលកសិកម្មដែលត្រូវបានរដ្ឋទូទាត់បន្ថែមដល់កសិករ។ ក្នុងឆ្នាំ១៩៨៨នៅប្រទេសជប៉ុន PSE ស្មើនឹង៧៤%នៃតម្លៃផលិតផលកសិកម្ម, នៅប្រទេសហ្វីលីពីន៧០%, នៅបណ្តាប្រទេសសហគមន៍អឺរ៉ុប ៤៦%, នៅប្រទេសនូវែលសេឡង់៨%។ សូចនាករផ្សេងទៀត គឺកម្រិតចំណាយរបស់រដ្ឋាភិបាលសម្រាប់កសិករម្នាក់ៗដែលប្រកបរបរកសិកម្ម។ ដោយហេតុថាចំនួនកសិករខុសគ្នានៅតាមប្រទេសនីមួយៗ នោះកម្រិតចំណាយសម្រាប់កសិករម្នាក់ៗក្នុងវិស័យកសិកម្មក៏មានភាពខុសគ្នាផងដែរ។ ជាក់ស្តែង ក្នុងអំឡុងឆ្នាំ១៩៨៤-១៩៨៦ នៅសហរដ្ឋអាម៉េរិកចំណាយគិតជាមធ្យមរបស់រដ្ឋាភិបាលសម្រាប់កសិករម្នាក់ៗស្មើនឹង៨,៨ពាន់ដុល្លារ នៅប្រទេសជប៉ុន ៨,៦ពាន់ដុល្លារ[13] ប៉ុន្តែ កសិករមិនបានទទួលប្រាក់ទាំងអស់នេះនៅក្នុងដៃឡើយ។ ក្រុមប្រឹក្សាជាតិអ្នកប្រើប្រាស់នៃចក្រភពអង់គ្លេសបានគណនាឃើញថា នៅក្នុងទីផ្សាររួមអឺរ៉ុបការចំណាយប្រចាំឆ្នាំសម្រាប់កសិកម្ម គឺតិចជាង១/២ បានទៅដល់ដៃកសិករ។ ក្នុងឆ្នាំ១៩៨៦ជិត២០%នៃថវិកាសរុបសម្រាប់វិស័យកសិកម្មរបស់សហគមន៍អឺរ៉ុប ត្រូវបានចំណាយទៅលើការរក្សាទុកផលិតផលអតិរេក( ផលិតផលលើសតម្រូវការ ) ចំណែក៤០%ផ្សេងទៀតនៃការឧបត្ថម្ភធនត្រូវបានប្រើប្រាស់សម្រាប់ជំរុញការនាំចេញ។ ដូច្នេះប្រាក់ទាំងអស់នោះនៅសល់ប្រមាណជា៤០% ប៉ុណ្ណោះដល់ដៃកសិករ[14]។

និន្នាការកើនឡើងនៃចំណាយរបស់រដ្ឋាភិបាលសម្រាប់គោលនយោបាយកសិកម្ម បានបង្ខំឱ្យប្រតិភូអាម៉េរិកនៅក្នុងជំនួបនៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធនិងពាណិជ្ជ(General Agreement on Tariffs and Trade, GATT)ឆ្នាំ១៩៨៧ ស្នើឡើងនូវការជំទាស់ចំពោះការឧបត្ថម្ភធនដល់វិស័យកសិកម្មចាប់ពីឆ្នាំ២០០០ ដែលធ្វើឱ្យមានប្រតិកម្មភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ក្រោយមកប្រទេសចំនួន៩៦ ជាសមាជិក GATT បានអនុម័តិមិនបង្កើនចំណាយនាពេលអនាគតសម្រាប់ការឧបត្ថម្ភធនដល់វិស័យកសិកម្ម ផ្ទុយទៅវិញ មានបំណងកាត់បន្ថយទាំងអស់ ជាពិសេសទាក់ទងនឹងការឧបត្ថម្ភធនសម្រាប់ការនាំចេញកសិផលចំនួនថេរ ដែលធ្វើឱ្យតម្លៃកសិផលនៅលើទីផ្សារពិភពលោកធ្លាក់ចុះ។

ទោះជាយ៉ាងណាក៏ដោយ ការរីកចម្រើនវិស័យកសិកម្មនៅសហរដ្ឋអាម៉េរិក គឺដោយសារតែការរីកចម្រើនបច្ចេកវិទ្យា ដូចជា អគ្គិសនីយកម្ម និងយន្តូបនីយកម្មកសិដ្ឋាន បច្ចេកទេសកាន់តែល្អប្រសើរឡើងក្នុងការប្រើប្រាស់ដី ការគ្រប់គ្រងនិងអភិរក្សដីកសិកម្ម ប្រព័ន្ធធារាសាស្ត្រ ការអភិវឌ្ឍជ្រើសរើសពូជដំណាំ ការធ្វើជីថ្មីឱ្យកាន់តែមានជីជាតិនិងថ្នាំសម្លាប់សត្វល្អិត ការធ្វើឱ្យកាន់តែប្រសើរឡើងនូវការបង្កាត់ពូជ និងថែទាំសត្វពាហនៈ ដែលទាំងអស់នេះហើយជាមូលដ្ឋានគ្រឹះនិងចលករសម្រាប់ការរីកចម្រើនវិស័យកសិកម្មរបស់អាម៉េរិកនាពេលបច្ចុប្បន្ន ហើយដែលធ្វើឱ្យកសិករអាម៉េរិកម្នាក់ៗអាចផ្គត់ផ្គង់សម្រាប់ចំនួនមនុស្សកាន់តែច្រើនឡើងពី៤នាក់ក្នុងឆ្នាំ១៨២០ រហូតដល់អាចផ្គត់ផ្គង់មនុស្សចំនួន១២៥នាក់ក្នុងឆ្នាំ១៩៩៤។

---

[11] Feedsuffs. Minneapolis. 1988. No. 25. P.43. ( -ដ- )

[12] Producer Subsidy Equivalent, PSE(CAP under fire in ew consumer report // Agra Europe. London, 1898. No 1302 P. E/1.( -ដ-, ទំព័រ១៨៨ )

[13] Landwiirtsschaftsblatt Weser-Ems. Oldenburg, 1989. Nr 6. S. 12. ( -ដ-, ទំព័រ១៨៩ )

[14] Cap under fire in new consumer report // Agra Europe. London, 1988. No. 1302. P. E/1.( -ដ- )

គប្បីបញ្ជាក់ផងដែរថា ការរីកចម្រើនបច្ចេកវិទ្យានៅសហរដ្ឋអាម៉េរិកបានកើតឡើងមានកម្រិតខ្ពស់ គឺមិនមែនដោយសារការផ្តួចផ្តើមរបស់កសិករនោះទេ ប៉ុន្តែគឺជាលទ្ធផលនៃការផ្តល់ហិរញ្ញប្បទានរបស់រដ្ឋាភិបាលពោលអន្តរាគមន៍របស់រដ្ឋាភិបាលនៅក្នុងវិស័យកសិកម្ម។ សហរដ្ឋអាម៉េរិកមាន"កម្មវិធីកសិកម្ម"សម្រាប់ឧបត្ថម្ភធនដល់កសិករ ដូចជា ថ្លៃកសិផល ប្រាក់ចំណូល និងផលិតផល, ការថែរក្សាទឹកនិងដី, ការស្រាវជ្រាវវិស័យកសិកម្ម, ការផ្តល់ឥណទានដល់កសិករ, ការធានារ៉ាប់រងដំណាំ, ការឧបត្ថម្ភធនសម្រាប់ការលក់ផលិតផលកសិកម្មនៅលើទីផ្សារពិភពលោក ជាដើម។ ក្នុងចំណោមកម្មវិធីទាំងនេះ "ថ្លៃនិងប្រាក់ចំណូលរបស់កសិករ" គឺជាបញ្ហាអាទិភាពដែលរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ជាពិសេស។ ជាក់ស្តែងការឧបត្ថម្ភធនក្នុងវិស័យកសិកម្មឆ្នាំ១៩៨៥ សម្រាប់រយៈពេលប្រាំឆ្នាំ មានចំនួន៨០ពាន់លានដុល្លារ($80 billion) និងក្នុងឆ្នាំ១៩៩០ចំនួន៤០-៥០ពាន់លានដុល្លារ($40-50billion)។ ក្នុងឆ្នាំ១៩៩២ប្រាក់ចំណូលរបស់កសិករចំនួន១/៣ គឺបានមកពីឧបត្ថម្ភធនរបស់រដ្ឋធៀបនឹងឆ្នាំ១៩៨៧ ដែលមានត្រឹមតែ២/៥ប៉ុណ្ណោះ និងរហូតដល់បច្ចុប្បន្នរដ្ឋាភិបាលសហព័ន្ធចំណាយជាង២០ប៊ីលានដុល្លារក្នុង១ឆ្នាំទៅលើឧបត្ថម្ភធនសម្រាប់កសិកម្ម[15] ជាពិសេសរដ្ឋាភិបាលការពារកសិករពីការឡើងចុះថ្លៃ ប្រាក់ចំណូល និងទិន្នផល។ រដ្ឋាភិបាលឧបត្ថម្ភសម្រាប់ពង្រឹងការអភិរក្ស ការធានាទូទាត់សង ទីផ្សារកិច្ច ការនាំចេញ ការស្រាវជ្រាវនិងសកម្មភាពផ្សេងៗទៀត៕

## សន្និដ្ឋាន

វិស័យកសិកម្មនៅកម្ពុជា ធៀបទៅនឹងវិស័យកសិកម្មនៅបណ្តាប្រទេសមួយចំនួននៅអឺរ៉ុបនិងអាម៉េរិក គឺមិនទាន់មានគោលនយោបាយកសិកម្មគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ប្រជាកសិករកម្ពុជានៅឡើយ។ ដូច្នេះដើម្បីលើកកម្ពស់វិស័យកសិកម្ម ចាំបាច់ត្រូវមានគោលនយោបាយកសិកម្មនិងឧបត្ថម្ភធនរបស់រដ្ឋាភិបាលដូចនៅបណ្តាប្រទេសមួយចំនួននៅអឺរ៉ុបនិងនៅសហរដ្ឋអាម៉េរិក ដើម្បីធានាពីការឡើងចុះថ្លៃនិងប្រាក់ចំណូលកសិករ ទិន្នផល ការធានាទូទាត់សង ទីផ្សារកិច្ច ការនាំចេញ ការស្រាវជ្រាវនិងសកម្មភាពផ្សេងៗទៀតសំដៅលើកកម្ពស់ប្រាក់ចំណូលនិងជីវភាពប្រជាកសិករ៕

ឲ្យឲ្យ❋ᨠᨠ

## ឯកសារយោង


១. *«ГОСУДАРСТВО И РЫНОК», Издательство С.-Перербургского Университета, С.ПЕТЕРБУРГ, 1995.*

២. *Народное хозяйство СССР в 1988 г. М., 1989.*

៣. *Саусановичус А. И., Демин А. А. Экономика сельского хозяйства// Экономики «разных скоростей». Капиталистические и развивающиеся страны : Очерки / Под ред. А. А. Демина. Л., 1990.*

៤. *Agra Europe. London, 1988. No. 1302.*

៥. *Agricultural Outlook.Washington. August 1989.*

៦. *Agriculture in the GATT: an analysis of alternative approaches to reform. Washingtob,1988.*


[15] https://www.downsizinggovernment.org/agriculture/subsidies

໗. Feedsuffs. Minneapolis. 1988. No. 25.

໘. Henrichsmever W., Ostermeyer – Schöder A., Productivity growth and factor adjustment in EC agriculture || European review of agricultural economics. 1988.

໙. Landwiirtsschaftsblatt Weser-Ems. Oldenburg, 1989. Nr 6.

໑໐. Monatsberichte Über die österreichische Landwirtschaft. Wien,1988.

໑໑. Richards E. Fünf Jahre Feform der Milchmarktpolitik // Kraftfutter. Hannover, 1989.

໑໒. Thied C. Landwirtschaftliche Vielfach in Europa – Wirtschaftliche und soziale Perspektiven // Geschäfts – und Arbeitsbericht der Agrarsonzialen Gesellschaft e. V. Göttingen fÜr das jahr 1988. Göttingen,1988.